**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាក្នុងដំណើរទស្សនៈកិច្ចជាមួយនិស្សិតសាលាសន្តយ៉ូស្ទីននៅប្រទេសម៉ាឡេស៊ី**
**ថ្ងៃទី៣០ កក្កដា ២០១៧**

អត្ថបទទី១៖ ១ពង្ស ៣,៥.៧-១២
អត្ថបទទី២៖ រម ៨,២៨-៣០
ដំណឹងល្អ៖ មថ ១៣,៤៤-៥២

បងប្អូនជាទីស្រឡាញ់!

ខ្ញុំជឿថាយប់មិញ យើងបានធ្វើបទពិសោធន៍អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ មិនមែនជាពាក្យមួយដែលយើងនិយាយទូទៅ ប៉ុន្តែ យើងបានឃើញជាក់ស្តែង នៅពេលដែលយើងឃើញជាងដប់ មឺននាក់ដែលមកពីគ្រប់ទីកន្លែង មកពីម៉ាឡេស៊ី មកពីសឹង្ហបុរី មកពីថៃ មកពីឥណ្ឌូនេស៊ី មកពីប្រទេសកម្ពុជា ជាដើម។ យើងឃើញបងប្អូនដែលជាគ្រីស្តបរិស័ទ បងប្អូនដែលមកពីសាសនាដទៃ ដែល ណែនាំឲ្យយើងយល់ថា **ពិតមែនព្រះយេស៊ូបានណែនាំឲ្យយើងជួបជុំគ្នា ឲ្យយើងចូលរួមនៅក្នុងមហាគ្រួសារតែមួយ**

អម្បាញ់មិញ យើងបានស្តាប់គម្ពីរដំណឹងល្អ **ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាពេជ្រមួយ ជាកំណប់មួយ ដែលមានតម្លៃលើសលប់** ដោយសារតម្លៃនេះយើងមិនអាចរាប់បានទេ។ ពីយប់មិញបទពិសោធន៍ដែលយើងមានជាមួយបងប្អូនទាំងអស់ អភិបូជាដែលយើងថ្វាយនៅពេលនេះដែរ ជាបទពិសោធន៍មួយដែលយើងរាប់មិនបាន ប៉ុន្តែយើងយល់ឃើញថា ពិតមែនព្រះជាម្ចាស់ស្រឡាញ់យើង ហើយយើងកំពុងធ្វើបទពិសោធន៍អំពីសេចក្តីស្រឡាញ់នេះ។

យើងបានឃើញចំណងជើង "**សូមធ្វើជាសាវ័ក នៃសេចក្តីសង្ឃឹម**។ ប៉ុន្តែនៅពេលយើងថាធ្វើជាសាវ័ក ឲ្យយើងមើលឃើញដល់ព្រះនាងម៉ារី ដោយសារព្រះនាងម៉ារីជាសាវ័កមុនគេបង្អស់។ នៅក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ គឺព្រះនាងម៉ារី ដែល បានឆ្លើយមុនគេបង្អស់ "ចាស! ខ្ញុំធ្វើជាមាតានៃព្រះជាម្ចាស់បាន"។ ព្រះនាងម៉ារី អាចធ្វើបានដោយសារៈ

**ទីមួយ** ព្រះនាងម៉ារី ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

**ទីពីរ** ព្រះនាងម៉ារីសុខចិត្ត ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនត្រឹមតែស្តាប់ ប៉ុន្តែធ្វើតាមអ្វីដែលព្រះនាងម៉ារី បានស្តាប់និងអនុវត្តន៍។ នៅក្នុងការអនុវត្ត ព្រះនាងម៉ារី បម្រើ និងស្រឡាញ់។ បម្រើព្រះយេស៊ូ ស្រឡាញ់ព្រះយេស៊ូ បម្រើបងប្អូនឯទៀតៗ

ស្រឡាញ់បងប្អូនឯទៀតៗ។ ពីរសប្តាហ៍ទៀត យើងគោរពព្រះនាងម៉ារីឡើងស្ថានបរមសុខ ជាពេលវេលាមួយដែលព្រះនាងម៉ារី ចូលទៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់តែម្តង។ ជាពេលវេលាមួយដែលព្រះនាងម៉ារី ទៅជាអង្គតែមួយជាមួយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ សម្រាប់យើង ជាឱកាសមួយដើម្បីគិត **តើយើងធ្វើដូចម្តេចដើម្បីទៅជាព្រះហឫទ័យស្រឡាញ់ដើម្បីធ្វើជាព្រះបេះដូងស្រឡាញ់របស់ព្រះយេស៊ូលើផែនដីនេះ?**

នៅពេលដែលយើងនិយាយអំពីសារកែនៃសេចក្តីស្រឡាញ់ នៃសេចក្តីសង្ឃឹម យើងអាចពិនិត្យមើលព្រះនាងម៉ារីម្តងទៀត ដោយសារព្រះនាងម៉ារីបានថែរក្សាសេចក្តីសង្ឃឹមជានិច្ច។ នៅពេលដែលព្រះនាងម៉ារីជិតដល់ពេលឆ្លងទន្លេ ព្រះនាងម៉ារីអត់មានកន្លែងនៅ ហើយប្រសិនបើយើងគិត បងប្អូនដែលមានផ្ទៃពោះហើយ ដែលធ្លាប់ឆ្លងទន្លេ ពេលអត់មានកន្លែងនៅដើម្បីឆ្លងទន្លេពិបាកណាស់។ យើងមានមណ្ឌលសុខភាព មានមន្ទីរពេទ្យ ក៏ប៉ុន្តែព្រះនាងម៉ារីអត់មានអីសោះ។ ប៉ុន្តែព្រះនាងម៉ារី បានរកឃើញកន្លែងមួយ និងព្រះនាងម៉ារីមានអំណរសប្បាយដោយសារឃើញកូនរបស់គាត់ កើតមកដោយមានសុខភាពល្អ។ នៅពេលព្រះនាងម៉ារីសម្រាលកូនហើយ ប្រហែលប្រាំបីថ្ងៃ ធ្វើដំណើរទៅណាសារ៉ែតមិនបាន ព្រះនាងម៉ារីចេញដំណើរទៅប្រទេសអេស៊ីប។ ព្រះនាងម៉ារី ទៅជាជនភៀសខ្លួនមុនគេបង្អស់ ជាមួយលោកយ៉ូសែប ជាមួយទារកយេស៊ូ។ តែព្រះនាងម៉ារីមិនបាត់បង់ក្តីសង្ឃឹម ទោះបីគាត់ទៅប្រទេសមួយដែលគាត់មិនស្គាល់ ដូចយើងបានស្តាប់បទពិសោធន៍របស់បងប្អូននៅប្រទេសម៉ាឡេស៊ី ជាកម្មករដែលមកពីប្រទេសនានា។

ព្រះនាងម៉ារី នៅកាណាក៏ដូចគ្នាដែរ! គេអស់ស្រាដើម្បីញ៉ាំ ពេលអស់ស្រាមានន័យថា ពិធីមង្គលការលែងសប្បាយអស់ហើយ។ ប៉ុន្តែព្រះនាងម៉ារី មិនអស់សង្ឃឹមទេ ព្រះនាងម៉ារីមានសេចក្តីសង្ឃឹមទៀត ដោយថែរក្សា ដោយយកចិត្តទុកដាក់ ដោយទទួលខុសត្រូវ ដោយថាសូមស្តាប់កូនរបស់ខ្ញុំ នៅពេលគាត់និយាយធ្វើតាមគាត់ទៅ។

នៅទីបំផុត នៅពេលព្រះនាងម៉ារីនៅក្បែរឈើឆ្កាង នៅពេលនោះសម្រាប់អ្នកជាមាតា ជាបទពិសោធន៍មួយដែលពិបាកបំផុត ដែលមើលកូនកំពុងស្លាប់ និងព្រះនាងម៉ារីនៅក្បែរឈើឆ្កាងដោយការពារថែរក្សាសេចក្តីសង្ឃឹម។ ដោយសារព្រះនាម៉ារី បានដឹងថា ព្រះ

ជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារី ព្រះជាម្ចាស់បានគង់នៅជាមួយព្រះនាងម៉ារី និងមិនអាចបោះបង់ចោលទាំងនាងម៉ារី ទាំងព្រះយេស៊ូដែរ។

ហេតុនេះហើយ យើងត្រូវតែបន្តធ្វើដំណើរនៅក្នុងពិភពលោកនេះ ដើម្បីធ្វើជាសាក្សីនៃសេចក្តីសង្ឃឹម ដោយសារ**ប្រសិនបើយើងមិនធ្វើ តើអ្នកណាធ្វើបាន?** ប្រសិនបើយើងទៅជាសាក្សីនៃសេចក្តីសង្ឃឹម នរណាធ្វើបាន? នៅពេលខ្ញុំស្តាប់បងប្អូនធ្វើបទពិសោធន៍ប៉ុន្មានថ្ងៃមុន ដែលមានព្រះសហគមន៍ធ្វើការស្វាគមន៍កម្មករដែលមកពីប្រទេសនានា ដែលស្វាគមន៍ជនភៀសខ្លួនដែលអត់មានកន្លែងត្រឹមត្រូវនៅក្នុងសង្គម ខ្ញុំគិតថាពិតមែនព្រះសហគមន៍របស់យើងជាទីតាំងមួយយ៉ាងពិសេស ដើម្បីទទួលការកក់ក្តៅ ដើម្បីទទួលការគោរព និងដើម្បីទទួលសេចក្តីសង្ឃឹមជានិច្ច។

ខ្ញុំជឿថា ព្រះសហគមន៍របស់យើងត្រូវទៅជា សញ្ញាសម្គាល់ពិសេសសម្រាប់សង្គមបច្ចុប្បន្ននេះ។ កាលពីយប់មិញ យើងបានផ្ញើជីវិតទាំងស្រុងទៅលើព្រះរាជ្យវង្សដ៏វិសុទ្ធក្រុមគ្រួសារដ៏វិសុទ្ធ ទៅលើព្រះនាងម៉ារី សន្តយ៉ូសែប និងព្រះយេស៊ូ សម្រាប់ម៉ាឡេស៊ីសម្រាប់ប្រទេសយើង សម្រាប់ទ្វីបអាស៊ីយើងទាំងអស់ ដើម្បីឲ្យគ្រួសារទាំងឡាយអាចរកឃើញសេចក្តីសុខសាន្ត។

ថ្ងៃនេះ យើងអធិដ្ឋានទូលអង្វរព្រះជាម្ចាស់តាមរយៈ សន្តីអាណា តាមរយៈ តាមរយៈសន្តយ៉ូហានគីម ដើម្បីបង្កើតពិភពថ្មី គឺពិភពរបស់ព្រះជាម្ចាស់។ អាមែន៕